# ព្រូដិនសល ដាក់ដំណើរការផលិតផលធានារ៉ាប់រងអាយុជីវិតលើគ្រោះថ្នាក់ចរាចរណ៍តាមប្រព័ន្ធឌីជីថលដំបូងគេនៅកម្ពុជា

ប្រភពឯកសារ ៖ [កាសែតកោះសន្តិភាព]

គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក គឺជាកត្តាចម្បងមួយនៃការស្លាប់ និងរបួសនៅព្រះរាជាណាចក្រកម្ពុជា ដែលជាមធ្យមមានចំនួន ១៣.៧០០ នាក់ ទទួលរងរបួស និងមរណភាពចំនួន ៥.៤ នាក់ ជារៀងរាល់ថ្ងៃ ។ មិនត្រឹមតែប៉ុណ្ណោះ ការចំណាយលើការថែទាំសុខភាពនៅឆ្នាំ ២០២០ មានទំហំជាទឹកប្រាក់ដល់ទៅ ៨០០ លានដុល្លារអាមេរិក សម្រាប់ករណីដែលតម្រូវឱ្យមានការស្នាក់នៅព្យាបាលនៅមន្ទីរពេទ្យ និងសេវាវេជ្ជសាស្ត្រផ្សេងៗ ដែលនេះជាចំណាយដែលប្រជាជនជាច្រើនត្រូវចំណាយដោយខ្លួនឯង ។

ដើម្បីជួយប្រជាជនកម្ពុជាក្នុងការរៀបចំផែនការហិរញ្ញវត្ថុ សម្រាប់គ្រោះថ្នាក់ដែលមិននឹកស្មានដល់ ក្រុមហ៊ុនព្រូដិនសលកម្ពុជា ដែលជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតឈានមុខគេនៅកម្ពុជាបានដាក់ដំណើរការនូវផលិតផលធានារ៉ាប់រង PRU សុវត្ថិភាពខ្ញុំ ដែលជាកញ្ចប់ធានារ៉ាប់រងអាយុជីវិតផ្ទាល់ខ្លួនតាមប្រព័ន្ធឌីជីថលដែលប្រកបដោយភាពច្នៃប្រឌិតខ្ពស់ ។

ផលិតផលធានារ៉ាប់រង PRU សុវត្ថិភាពខ្ញុំ ផ្តល់អត្ថប្រយោជន៍សម្រាប់ហេតុការណ៍ដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍ដូចខាងក្រោម ៖

១. ករណីបាក់ឆ្អឹង

២. ករណីបាត់បង់ដៃ/ជើងម្ខាង

៣. អត្ថប្រយោជន៍ករណីសម្រាកព្យាបាលនៅមន្ទីរពេទ្យប្រចាំថ្ងៃ ដែលបណ្តាលមកពីគ្រោះថ្នាក់ចរាចរណ៍

៤. ករណីមរណភាព ឬពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ដោយសារគ្រោះថ្នាក់ចរាចរណ៍ ។

## I. Vocabulaire : Retrouvez les bonnes traductions des mots ci-dessous :

| | | | | | |
|---|---|---|---|---|---|
| ទាមទារសំណង | ផលិតផលធានារ៉ាប់រងអាយុជីវិត | ប្រព័ន្ធឌីជីថល | ផ្លូវគោក | កត្តាចម្បង | ជាមធ្យម |
| មរណភាព | សេវាវេជ្ជសាស្ត្រ | ហិរញ្ញវត្ថុ | បណ្ណសន្យារ៉ាប់រង | អតិថិជន | |

| | | | | |
|---|---|---|---|---|
| Assurance de santé | La finance | La route | Mourir | Réclamer le remboursement |
| Le facteur principal | Les clients | En moyen | La carte d’assurance | Système numérique |
| Services médicaux | | | | |

## II. Production écrite.

សម្រាប់អ្នកផ្ទាល់តើអ្នកគិតថាការទិញសេវាធានារ៉ាប់រងមានសារៈសំខាន់ដែរឬទេ? ចូរពន្យល់។

**Personnellement, pensez-vous qu'il est important de souscrire une assurance ? Expliquez.**

## III. Lecture

**Lisez le texte en l’enregistrant puis envoyez-le-moi via Google Classroom.**

Pour enregistrer, utilisez : https://vocaroo.com/